# ការការពារជនស៊ីវិល ក្នុងបទឧក្រិដ្ឋកម្មអន្តរជាតិ

១. បទល្មើសក្រោមច្បាប់ជាតិ ជាទូទៅប៉ះពាល់ជនរងគ្រោះជាបុគ្គល។ ក៏ប៉ុន្តែ បទឧក្រិដ្ឋកម្ម ក្រោមច្បាប់អន្តរជាតិប៉ះពាល់បុគ្គល ជាក្រុម អាចជាក្រុមពូជសាសន៍ ឬសាសនាជាដើម។

២. បទឧក្រិដ្ឋកម្មសង្គ្រាម (War Crime:WC) និងប្រឆាំងនឹងមនុស្សជាតិ (Crime against Humanity: CaH)[1] ចែងការពារជនស៊ីវិល ជាប្រភេទមនុស្សស្ថិតក្នុងក្រុមត្រូវបានការពារ (protected persons)។ WC មិនហាមឃាត់ការសម្លាប់ទាហាននៃប្រទេសគូសត្រូវ ដែលកំពុងប្រយុទ្ធទេ។ នេះក្នុងន័យថា ការសម្លាប់ទាហាន មិនខុសច្បាប់។ ក៏ប៉ុន្តែ ប្រសិនបើសម្លាប់ជនស៊ីវិលនៃប្រទេសគូសត្រូវ (ឬរបស់ប្រទេសផ្សេងគ្មានទំនាក់ទំនងការទូត) ស្ថិតក្នុងការកាន់កាប់របស់ខ្លួន ឬចាប់ពួកគេដាក់ជារបាំងខែលការពារ (human shield) នេះជាការបំពានច្បាប់ ដែលចាត់ថាជាបំពារបំពានធ្ងន់ (grave breach) ជាបទឧក្រិដ្ឋមួយនៃ WC។ ដូចគ្នានេះដែរ សម្រាប់ CaH ការវាយប្រហារលើជនស៊ីវិល ជាទង្វើខុសវិធានច្បាប់អន្តរជាតិ។

៣. ជនស៊ីវិលត្រូវបាន ផ្តល់ន័យថា៖ *ជនស៊ីវិល ជាមនុស្សម្នាក់មិនស្ថិតក្នុងក្រុមមនុស្ស ដែលចែងក្នុងមាត្រា ៤ (ក.១ ដល់ ៣ និង ៦) នៃអនុសញ្ញាទី៣ និងក្នុងមាត្រា ៤៣ នៃពិធីសារនេះ*[2] ។ អ្នកកាសែត ឬគ្រូពេទ្យ ត្រូវបានចាត់ថាជាជនស៊ីវិល។ ក្នុងករណីមានមនុស្សមួយចំនួនមិនមែនជាជនស៊ីវិល ដូចជា ទាហាននៅក្នុងនោះ ក៏ភាពជាស៊ីវិលនៃក្រុមមនុស្សនោះ មិនបាត់បង់ឡើយ។ ក្នុង WC ការកំណត់ថាជនស៊ីវិល មិនសំខាន់ទៅលើសញ្ជាតិទេ បើតាមយុត្តិសាស្ត្រ។ អ្វីសំខាន់គឺ ចំណងទាក់ទងពិតប្រាកដ រវាងជនស៊ីវិលនឹងប្រទេសណាមួយនៃគូរជម្លោះ (បុគ្គលមានសញ្ជាតិនៃប្រទេស *ក* តែចូលដៃជាមួយប្រទេស *ខ* ជាសត្រូវក្នុងសង្គ្រាមប្រឆាំងនឹងប្រទេស *ក*)។

៤. សម្រាប់ WC ជនស៊ីវិល នឹងបាត់បង់នូវឋានៈជាជនទទួលបានការការពារ ប្រសិនបើចូលរួមដោយផ្ទាល់ក្នុងជម្លោះប្រដាប់អាវុធ ហើយអាចជាកម្មវត្ថុនៃការវាយប្រហារ (attack target)។ ទោះបីជាយ៉ាងនេះក្តី ការវាយប្រហារអាចធ្វើទៅក្នុងពេលកំពុងកាន់អាវុធធ្វើសង្គ្រាម មិនមែនពេលដែល ជនស៊ីវិលនោះកំពុងសម្រាកទេ។ នេះខុសពី ទាហាន (combatants) ដែលអាចត្រូវបានវាយប្រហារនាពេលណាក៏បានក្នុងអំឡុងពេលមានសង្គ្រាម។

---

[1] អត្ថបទ ស្តីពី CaH ដោយនឹងត្រូវបានបោះពុម្ពនៅក្នុងគេហទំព័រនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[2] Article 50: 1. A civilian is any person who does not belong to one of the categories of persons referred to in Article 4 A (1), (2), (3) and (6) of the Third Convention and in Article 43 of this Protocol. In case of doubt whether a person is a civilian, that person shall be considered to be a civilian. 2. The civilian population comprises all persons who are civilians.3. The presence within the civilian population of individuals who do not come within the definition of civilians does not deprive the population of its civilian character. International Committee of the Red Cross (ICRC), *Protocol Additional to the Geneva Conventions of 12 August 1949, and relating to the Protection of Victims of International Armed Conflicts (Protocol I)*, 8 June 1977, 1125 UNTS 3, available at: https://www. Refworld . org/docid/3ae6b36b4.html [accessed 28 June 2020]

<u>កំណត់សំគាល់</u>៖ ៤. ការបកស្រាយពាក្យ “ជនស៊ីវិល ឬការវាយប្រហារជនស៊ីវិល” នៅតែជាបញ្ហា។ មានសំណួរផ្លូវច្បាប់នៅមុខសាលាក្តីខ្មែរក្រហម (អវតក) ថា៖ តើការវាយប្រហារលើទាហាន ដែលត្រូវបានចោទថាក្បត់នឹងរបបរបស់ខ្លួនដោយរបបខ្មែរក្រហម អាចចាត់ថាជាការវាយប្រហារលើជនស៊ីវិល ចូលក្នុងធាតុផ្សំចម្បង(chapeau elements) នៃ CaH ដែរឬយ៉ាងណា? http://www.measboralaws.com/detail/1079

<u>**ឯកសារយោង**</u>៖ Luisa Vierucci, *Protected Persons* (473-474), Knut Dormann, *Civilians (attacks on)* (pp. 263-264) in Antonio Cassese, the Oxford Companion to the International Criminal Justice, 2009; ECCC Case 003, Notification on the Interpretation of “Attack against the Civilian Population “in the Context of Crimes against Humanity with regard to a State’s or Regime’s own armed forces, D191/18, 7 February 2017 http://www.measboralaws.com/detail/1082។